# ការលើកទឹកចិត្តយុវជនវិនិយោគកសិកម្ម ប្រកបដោយការទទួលខុសត្រូវ នៅប្រទេសកម្ពុជា



ចងក្រងដោយ ក្នុងភាពជាដៃគូជាមួយ

គាំទ្រដោយ

Food and Agriculture Organization of the United Nations

AsiaDHRRA

ReCoERDO

សេចក្ដីបញ្ជាក់ ៖

" ឯកសារនេះត្រូវបានបោះពុម្ពផ្សាយ ដោយមានជំនួយពីអង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ សហភាពអឺរ៉ុប និងអង្គការអេស៊ាដ្រា។ ខ្លឹមសារនៃការបោះពុម្ពផ្សាយនេះគឺជាការទទួលខុសត្រូវរបស់ CamboDHRRA និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់អង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ សហភាពអឺរ៉ុប និងអង្គការអេស៊ាដ្រាឡើយ ។ "

បោះពុម្ពឆ្នាំ ២០២០

# អារម្ភកថា

ការចូលរួមរបស់យុវជនក្នុងវិស័យកសិកម្ម គឺជាប្រធានបទលេចធ្លោមួយនាពេលថ្មីៗនេះ ហើយបានបង្កើនរបៀបវារៈនៃការអភិវឌ្ឍន៍ខណៈដែលមានការព្រួយបារម្ភកាន់តែខ្លាំងឡើងនៅទូទាំងពិភពលោក ក៏ដូចជាប្រទេសកម្ពុជា ថាយុវជនបានក្លាយជាមនុស្សដែលមិនចូលចិត្តនឹងការងារកសិកម្ម។

ស្របពេលជាមួយគ្នានេះដែរ ចំនួនប្រជាជននៅតាមទីក្រុងមានការកើនឡើងជាលំដាប់ និងរីកចម្រើនឥតឈប់ឈរ រួមជាមួយនឹងមានការផ្លាស់ប្តូរផលិតកម្ម និងការប្រើប្រាស់ម្ហូបអាហារយ៉ាងខ្លាំងក្នុងលំនាំវិធីផ្សេងទៀត ដែលបង្កហានិភ័យដល់សន្តិសុខស្បៀងសម្រាប់មនុស្សគ្រប់រូបនាពេលអនាគត។ ដូច្នេះ កិច្ចការចាំបាច់បំផុតនោះគឺ ការគាំទ្រពីតួអង្គនានា និងអ្នកពាក់ព័ន្ធដើម្បីពង្រីកការវិនិយោគប្រកបដោយការទទួលខុសត្រូវនៅក្នុងប្រព័ន្ធកសិកម្ម និងស្បៀងអាហារ។

អង្គការអាស៊ាដ្រា(AsiaDHRRA) ក្នុងការងារកសាងកិច្ចសហប្រតិបត្តិការ និងពង្រឹងយន្តការឆ្ពោះទៅរកការសំរេចបាននៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) និងរបៀបវារៈទស្សវត្សរ៍កសិកម្មជាលក្ខណៈគ្រួសារ របស់អង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) បានចាប់ដៃគូជាមួយអង្គការ FAO ក្នុងការធ្វើមូលដ្ឋានីយកម្មនៃការគាំទ្រការវិនិយោគប្រកបដោយការទទួលខុសត្រូវក្នុងប្រព័ន្ធកសិកម្ម និងស្បៀងអាហារសម្រាប់ កម្មវិធីរបស់ខ្លួននៅអាស៊ីអាគ្នេយ៍។

សមាគមខាំបូដ្រា (CamboDHRRA) ដែលជាសមាជិករបស់អង្គការអេស៊ាដ្រា បានសហការជាមួយសមាជិករបស់ខ្លួនដើម្បីអនុវត្តន៍កម្មវិធី "ការពង្រឹងសមត្ថភាពនិងលើកកម្ពស់យុវជនក្នុងការវិនិយោគកសិកម្មប្រកបដោយការទទួលខុសត្រូវ (RAI) នៅក្នុងប្រទេសកម្ពុជា" ក្នុងគោលបំណងបង្កើនការយល់ដឹង និងធ្វើសកម្មភាពរួមគ្នាទាក់ទងនឹង RAI រួមមានការបង្កើនបរិយាកាសអំណោយផល ការពង្រឹងសមត្ថភាពដល់យុវជន ស្ត្រី និងភាគីពាក់ព័ន្ធធ្វើអោយប្រសើរឡើងនូវការត្រួតពិនិត្យ និងការវាយតម្លៃពីនិន្នាការ និងផលប៉ះពាល់នៃរបៀបវារៈនេះ ជាពិសេសពីសារៈសំខាន់នៃការចូលរួម និងផ្តល់អំណាចដល់យុវជន និងស្ត្រីក្នុងវិស័យកសិកម្ម។

ឯកសារនេះ គឺជាការចងក្រងអនុសាសន៍សំខាន់ៗ ដែលជាលទ្ធផលនៃសកម្មភាពបាននអនុវត្តរួមគ្នាកន្លងមកក្នុងការលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងវិស័យកសិកម្មដែលរួមមាន (១)សិក្ខាសាលាស្តីពីការវាយតំលៃសមត្ថភាពយុវជន និងការវិនិយោគកសិកម្មប្រកបដោយការទទួលខុសត្រូវនៅប្រទេសកម្ពុជា (២)សិក្ខាសាលាពិគ្រោះយោបល់ស្តីពីយុវជននិងទស្សនទានឆ្ពោះទៅអនាគតកសិកម្មកម្ពុជា និង(៣)ការសិក្សារហ័សស្តីពីយុវជន និងការវិនិយោគកសិកម្មប្រកបដោយការទទួលខុសត្រូវនៅកម្ពុជា។

សង្ឃឹមថា ឯកសារនេះនឹងអាចជាឯកសារយោងសម្រាប់ការរៀបចំក្របខ័ណ្ឌគោលនយោបាយ និងផែនការសកម្មភាពជាក់ស្តែងក្នុងការស្វែងរកដំណើរឆ្ពោះទៅរកការអភិវឌ្ឍកសិកម្ម និង ជនបទប្រកបដោយចីរភាព ។

យើងខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការស្បៀងនិងកសិកម្មនៃអង្គការសហប្រជាជាតិ សហភាពអឺរ៉ុប និង អង្គការអេស៊ាដ្រា សម្រាប់ការជឿទុកចិត្តក្នុងភាពជាដៃគូជាមួយយើងខ្ញុំសម្រាប់គំនិតផ្តួចផ្តើមនេះ។ សូមថ្លែងអំណរគុណដល់សមាជិកសមាគមខាំបូដ្រា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប ទីប្រឹក្សាឯករាជ្យ និងតួអង្គពាក់ព័ន្ធផ្សេងទៀត ដែលបានផ្តល់ធាតុចូល គំនិតផ្តួចផ្តើមនានា និងចូលរួមយ៉ាងសកម្មក្នុងសកម្មភាពដែលបានអនុវត្តរួមគ្នាកន្លងមក។

**ហ៊ឹម ឡឿន**

***អគ្គលេខាធិការ សមាគមខាំបូដ្រា***

# មាតិកា

ទំព័រ

**អារម្ភកថា**

**១. សេចក្តីផ្តើម** ........ ១

**២. គោលការណ៍របស់ CFS-RAI និងAGRAI** ........ ២

☛ គោលការណ៍ទាំង ១០ របស់គណៈកម្មាធិការសន្តិសុខស្បៀង អាហារពិភពលោកសម្រាប់ការវិនិយោគប្រកបដោយការទទួលខុសត្រូវក្នុងប្រព័ន្ធកសិកម្ម និងស្បៀងអាហារ (CFS-RAI)៖ ........ ២

☛គោលការណ៍ណែនាំរបស់អាស៊ាន ស្តីពីការវិនិយោគប្រកបដោយការទទួលខុសត្រូវលើវិស័យចំណីអាហារកសិកម្ម និងព្រៃឈើ(AGRAI) ........ ៣

**៣. ហេតុអ្វីយុវជនត្រូវចូលរួមលើការវិនិយោគកសិកម្មប្រកបដោយការទទួលខុសត្រូវ?** ........ ៤

**៤. អនុសាសន៍សំខាន់ៗមួយចំនួន ដើម្បីលើកទឹកចិត្តយុវជនចាប់យកអាជីពកសិកម្ម** ........ ៥

**៥. ករណីសិក្សា យុវជនក្នុងការវិនិយោគកសិកម្ម** ........ ១០

- បង្កើតការងារខ្លួនឯងក្រោយរៀនចប់នៅបរទេស
  លោក **វន សំភាស់** ........ ១០
- ឈប់ធ្វើការអោយគេដោយចំណាកស្រុក មកធ្វើការអោយខ្លួនឯង
  លោកស្រី **អ៊ុក សុភាព** ........ ១១
- នៅសិក្សាក៏អាចធ្វើការងារកសិកម្មបានដែរ
  កញ្ញា **ជា សៀងឡា** ........ ១២
- ឈប់ពីការងារដែលមានប្រាក់ខែមកធ្វើការអោយខ្លួនឯង
  លោក **ហ៊ុន ផានី** ........ ១៣

**ឯកសារយោង** ........ ១៤

# ១. សេចក្តីផ្តើម

ក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចប្រទេសកម្ពុជា កម្លាំងពលកម្មត្រូវបានបែងចែកជាបីប្រភេទសំខាន់គឺ (ទី១) ពលកម្មក្នុងវិស័យកសិកម្ម (ទី២) ពលកម្មក្នុងវិស័យឧស្សាហកម្ម និង (ទី៣)ពលកម្មក្នុងវិស័យសេវាកម្ម។ ជាការសង្កេតពលកម្មក្នុងវិស័យកសិកម្មបានកំពុងធ្លាក់ចុះគួរអោយគត់សម្គាល់។ កម្លាំងពលកម្មក្នុងវិស័យកសិកម្មឆ្នាំ២០១៣ មានចំនួន៤៨.៧% និង៣៧% នៅឆ្នាំ២០១៧ (ប្រភពទិន្នន័យពីវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ) ហើយចរន្តចំណាកស្រុកពីជនបទមកកាន់ទីក្រុង និងទៅក្រៅប្រទេសកំពុងមាននិន្នាកើនឡើង។ ម្យ៉ាងវិញទៀត ប្រទេសកម្ពុជា មានយុវជន(១៥-៣០ឆ្នាំ) មានប្រហែល ៣៣% នៃចំនួនប្រជាជនសរុប ដែលជាប្រជាសាស្ត្រដ៏មានសក្តានុពលដែលអាចនាំឱ្យមានកំណើនសេដ្ឋកិច្ច និងការផ្លាស់ប្តូរសង្គម។ យុវជនភាគច្រើនជាជនជាតិខ្មែរ (៩៦%) និង ៨៣% រស់នៅ តាមតំបន់ជនបទដែលភាគច្រើនរស់នៅក្នុងតំបន់បឹងទន្លេសាប និង វាលទំនាប ដែលជាប្រភពសំខាន់នៃ កសិកម្ម (ស្រូវ បសុសត្វ នេសាទ និងព្រៃឈើ) ( World Bank 2018) នេះបញ្ជាក់យ៉ាងច្បាស់ថាយុវជនមានទំនាក់ទំនង ជាមួយនឹងកសិកម្ម។

គណៈកមាធិការស្តីពីសន្តិសុខស្បៀងពិភពលោក (CFS) តាមរយៈដំណើរការពហុភាគីពាក់ព័ន្ធ បានអនុម័តគោលការណ៍ សម្រាប់ការវិនិយោគប្រកបដោយការទទួលខុសត្រូវក្នុងប្រព័ន្ធកសិកម្ម និងស្បៀងអាហារ(CFS-RAI) ដែលរួមមានគោលការណ៍ចំនួន ១០ ដែលអនុវត្តចំពោះគ្រប់ប្រភេទ និងទំហំទាំងអស់លើការវិនិយោគកសិកម្ម នៅគ្រប់ដំណាក់កាលនៃខ្សែសង្វាក់តម្លៃ។ វាដើរតួជាឧបករណ៍សំរាប់ដោះស្រាយ និងអនុវត្តសកម្មភាពលើបញ្ហាបរិស្ថាន សេដ្ឋកិច្ច សង្គម និងបញ្ហាដែលពាក់ព័ន្ធនឹងប្រព័ន្ធអាហាររបស់យើង។

ដើម្បីលើកកម្ពស់គោលការណ៍ និងគោលការណ៍ណែនាំស្តីពី ការវិនិយោគប្រកបដោយការទទួលខុសត្រូវលើប្រព័ន្ធកសិកម្ម និងស្បៀងអាហារ អង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ(FAO) បានចាប់ផ្តើមជំរុញអនុវត្តកម្មវិធីគាំទ្រការវិនិយោគប្រកបដោយការទទួលខុសត្រូវក្នុងប្រព័ន្ធកសិកម្មនិង ស្បៀងអាហារនៅឆ្នាំ២០១៧ ដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនានាទាក់ទងនឹងការលើកកម្ពស់ការវិនិយោគកសិកម្មដូចជា កង្វះការយល់ដឹងបញ្ហាប្រឈមនៃអភិបាលកិច្ច សមត្ថភាព និងគម្លាតព័ត៌មានជាដើម។

សកម្មភាពដំបូងអនុវត្តដោយកម្មវិធីរួមមាន ការអភិវឌ្ឍសម្ភារៈសិក្សា ការអភិវឌ្ឍសមត្ថភាពលើក្របខ័ណ្ឌច្បាប់ និងសកម្មភាពនានាដើម្បីផ្តល់អំណាចដល់យុវជន។

សមាគមខាំបូជ្រា តាមរយៈភាពជាដៃគូរវាង អង្គការអេស៊ាជ្រា ជាមួយអង្គការ FAO បានអនុវត្តសកម្មភាពសំខាន់ៗមួយចំនួន ដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងវិស័យកសិកម្ម ដែលរួមមាន (១)រៀបចំសិក្ខាសាលាស្តីពីការវាយតំលៃសមត្ថភាពយុវជន និងការវិនិយោគកសិកម្មប្រកបដោយការទទួលខុសត្រូវនៅប្រទេសកម្ពុជា (២)រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីយុវជន និងទស្សនទានឆ្ពោះទៅអនាគតកសិកម្មកម្ពុជា (៣)ការសិក្សារហ័សស្តីពីយុវជន និងការវិនិយោគកសិកម្មប្រកបដោយការទទួលខុសត្រូវនៅកម្ពុជា (៤)សម្របសម្រួលតំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងភាគីពាក់ព័ន្ធចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ស្តីពីតួនាទីរបស់យុវជននៅ CFS-RAI និង AGRAI នាទីក្រុងហាណូយ ប្រទេសវៀតណាម (៥)សម្របសម្រួលតំណាងសមាជិកសមាគមខាំបូជ្រា ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីយុវជន និងCFS-RAI និងAGRAI នាទីរាជធានីបាងកក ប្រទេសថៃ និងបានអនុវត្តន៍សកម្មភាពមួយចំនួនទៀត ក្នុងន័យលើកទឹកចិត្ត និងគាំទ្រយុវជនចូលរួមវិនិយោគកសិកម្ម។

## ២. គោលការណ៍របស់ CFS-RAI និងAGRAI

### គោលការណ៍ទាំង ១០

**របស់គណៈកម្មាធិការសន្តិសុខស្បៀងអាហារពិភពលោកសម្រាប់ការ វិនិយោគ ប្រកបដោយការទទួលខុសត្រូវក្នុងប្រព័ន្ធកសិកម្ម និង ស្បៀងអាហារ (CFS-RAI)៖**

- **គោលការណ៍ទី ១៖** ចូលរួមចំណែកដល់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ។
- **គោលការណ៍ទី ២៖** ចូលរួមចំណែក ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងចីរភាពព្រមទាំងការលុបបំបាត់ភាពក្រីក្រ។
- **គោលការណ៍ទី ៣៖** លើកកម្ពស់សមភាពយេនឌ័រ និងផ្តល់អំណាចដល់ស្ត្រី។
- **គោលការណ៍ទី ៤៖** លើកកម្ពស់ការចូលរួម និងផ្តល់អំណាចដល់យុវជន។
- **គោលការណ៍ទី ៥៖** គោរពសិទ្ធិកាន់កាប់ដីធ្លី ជលផល និងព្រៃឈើ និងការទទួលបានទឹក។
- **គោលការណ៍ទី ៦៖** អភិរក្សនិងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព បង្កើនភាពធន់ និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។
- **គោលការណ៍ ៧៖** គោរពបេតិកភណ្ឌវប្បធម៌ និងចំណេះដឹងបែបប្រពៃណី និងគាំទ្រពិពិធកម្ម និងការច្នៃប្រឌិត។
- **គោលការណ៍ទី ៨៖** លើកកម្ពស់ប្រព័ន្ធ កសិកម្ម និងស្បៀងអាហារប្រកបដោយសុវត្ថិភាពនិងសុខភាព។
- **គោលការណ៍ទី ៩៖** បញ្ចូលរចនាសម្ព័ន្ធ ដំណើរការអភិបាលកិច្ច និងយន្តការនៃបណ្តឹងសារទុក្ខ ប្រកបដោយបរិយាបន្ន និងមានតម្លាភាព។
- **គោលការណ៍ទី១០៖** វាយតម្លៃ និងដោះស្រាយផលប៉ះពាល់ និងលើកកម្ពស់គណនេយ្យភាព។


ផ្ទះលេខ២៨ ផ្លូវលេខ១០០៧ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ . #28, street 1007, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
Mobile: (+855) 17 451 564 / (+855 98 452 581) . Facebook: ខំប្ញជា/Cambodhrra / Cambo DHRRA . www.cambodhrra.org

# គោលការណ៍ណែនាំរបស់អាស៊ានស្តីពី ការវិនិយោគប្រកបដោយការទទួលខុសត្រូវលើវិស័យចំណីអាហារ កសិកម្ម និងព្រៃឈើ (AGRAI)

- **គោលការណ៍ណែនាំទី១៖** រួមចំណែកដល់សន្តិសុខស្បៀងអាហារសុវត្ថិភាពនិងអាហារូបត្ថម្ភល្អប្រសើរ។
- **គោលការណ៍ណែនាំទី២៖** រួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងការលុបបំបាត់ភាពក្រីក្រប្រកបដោយចីរភាព សមធម៌ និងបរិយាបន្ន។
- **គោលការណ៍ណែនាំទី៣៖** លើកកម្ពស់សមភាព ការចូលរួម និងផ្តល់អំណាចដល់ស្ត្រី យុវជន ជនជាតិដើមភាគតិច និងក្រុមដែលត្រូវបានផាត់ចោល។
- **គោលការណ៍ណែនាំទី៤៖** គោរពសិទ្ធិកាន់កាប់ដីធ្លី ជលផល និងព្រៃឈើ និងការទទួលបានទឹក។
- **គោលការណ៍ណែនាំទី៥៖** រួមចំណែកដល់ការអភិរក្ស និងការគ្រប់គ្រងប្រកបដោយចីរភាពនូវធនធានធម្មជាតិជាពិសេសព្រៃឈើ។
- **គោលការណ៍ណែនាំទី៦៖** គាំទ្រដល់បច្ចេកវិទ្យា និងទម្លាប់អនុវត្តន៍ប្រកបដោយចីរភាព និងសមស្របចំពោះប្រព័ន្ធចំណីអាហារ កសិកម្ម និងព្រៃឈើ ដែលមានប្រសិទ្ធិភាពផ្នែកធនធានប្រកបដោយផលិតភាព និងប្រសិទ្ធិភាព។
- **គោលការណ៍ណែនាំទី៧៖** បង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ គ្រោះធម្មជាតិ និងហេតុការណ៍នាំអោយតក់ស្លុតផ្សេងទៀត។ ទន្ទឹមនឹងនោះរួមចំណែកដល់ការកាត់បន្ថយ និងការបន្សុំានឹងការប្រែប្រួលអាកាសធាតុ។
- **គោលការណ៍ណែនាំទី៨៖** គោរពនីតិរដ្ឋ និងបញ្ចូលរចនាសម្ព័ន្ធ ដំណើរការអភិបាលកិច្ច និងយន្តការនៃបណ្តឹងសារទុក្ខប្រកបដោយបរិយាបន្ន និងមានតម្លាភាព។
- **គោលការណ៍ណែនាំទី៩៖** យន្តការនានាដើម្បីវាយតម្លៃ និងដោះស្រាយផលប៉ះពាល់បរិស្ថាន និងវប្បធម៌ និងលើកកម្ពស់គណនេយ្យភាព គោរពចំពោះជនងាយរងគ្រោះក្រុមជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។
- **គោលការណ៍ណែនាំទី១០៖** ពង្រឹងអភិក្រមក្នុងតំបន់ ចំពោះការវិនិយោគប្រកបដោយការទទួលខុសត្រូវលើចំណីអាហារ កសិកម្ម និងព្រៃឈើ នៅក្នុងអាស៊ាន។

## ៣. ហេតុអ្វីយុវជនត្រូវចូលរួមលើការវិនិយោគកសិកម្មប្រកបដោយការទទួលខុសត្រូវ?

ក្រៅពីការពង្រឹងសមត្ថភាពរបស់កសិករខ្នាតតូច អ្នកផលិត ដើម្បីវិនិយោគ និងទទួលបានអត្ថប្រយោជន៍ពីការវិនិយោគកសិកម្មប្រកបដោយការទទួលខុសត្រូវការជំរុញការចូលរួម និងផ្តល់អំណាចដល់យុវជនក៏ជាវិធីសាស្រ្ត ដែលនាំអោយយុវជនចាប់អារម្មណ៍ចូលរួមក្នុងវិស័យកសិកម្មឡើងវិញ ហើយជាបន្តបន្ទាប់ផលិតកម្មស្បៀងអាហារពិភពលោកនឹងកើនឡើង (ដូចដែលផលិតកម្មត្រូវការកើនឡើង ៦០% នៅឆ្នាំ ២០៥០) ។ ម្យ៉ាងទៀត ផ្តល់សិទ្ធិអំណាចដល់យុវជនរួមទាំងសហគ្រិនកសិកម្ម និងកម្មករ ដើម្បីចូលរួមការវិនិយោគវិស័យកសិកម្ម ក៏ជួយកាត់បន្ថយភាពអត់ការងារធ្វើ និងបង្កើតការងារសម្រាប់យុវជនផងដែរ ព្រមទាំងកាត់បន្ថយការធ្វើចំណាកស្រុកនៅជនបទ ទីក្រុង និងអន្តរជាតិ(FAO, ២០១៩)។

ទោះយ៉ាងណាក៏ដោយ មានឧបសគ្គធំៗមួយចំនួន ក្នុងការធ្វើឱ្យយុវជនចូលរួមក្នុងវិស័យកសិកម្មដែលត្រូវការជំនះជាដំបូង ទាំងនោះគឺ៖

- សមត្ថភាពផ្ទាល់ខ្លួន / បុគ្គលមានកំណត់ (ជំនាញ និងចំណេះដឹងក្នុងផលិតកម្មកសិកម្ម កែច្នៃ ទីផ្សារ។ ល។ ) របស់យុវជន។
- មានអង្គការ ឬអង្គការដឹកនាំដោយយុវជនដែលធ្វើការជាមួយយុវជនតិចតួច ដើម្បីផ្តល់សេវាកម្មសំខាន់ៗដែលពួកគេត្រូវការ។
- បរិយាកាសអំណោយផលមានតិចតួច ដូចជា ស្ថាប័ន ច្បាប់គោលនយោបាយ ដែលលើកទឹកចិត្ត និងជំរុញឱ្យមានការចូលរួមរបស់យុវជននៅក្នុងវិស័យកសិកម្ម។

ការរួមបញ្ចូលគ្នានៃកត្តាទាំងបីនេះ ដាក់កម្រិតយ៉ាងខ្លាំង ដល់សមត្ថភាពរបស់យុវជនក្នុងការវិនិយោគ និងទទួលបានអត្ថប្រយោជន៍ពីការវិនិយោគលើវិស័យកសិកម្ម។ កត្តាទាំងនេះក៏កំណត់យុវជនផងដែរ ក្នុងការទទួលបានដី ហិរញ្ញវត្ថុ ឥណទាន និងទីផ្សារ ដែលចាំបាច់ដើម្បីទទួលបានជោគជ័យក្នុងវិស័យកសិកម្ម។ (FAO, ២០១៩)

## ៤. អនុសាសន៍សំខាន់ៗមួយចំនួន ដើម្បីលើកទឹកចិត្តយុវជនចាប់យកអាជីពកសិកម្ម

### បង្កើតឱកាសបណ្តុះបណ្តាលបន្ថែមទៀតសម្រាប់កម្មវិធីអភិវឌ្ឍន៍សហគ្រិនភាពកសិកម្ម



### លើកកម្ពស់កសិកម្មជាអាជីពថ្លៃថ្នូរ និងការរស់នៅប្រកបដោយភាពសម្បូរណ៍សប្បាយ



## ភាពងាយស្រួលក្នុងការទទួលបានដើមទុន ដីធ្លី បច្ចេកវិទ្យា និងព័ត៌មាន




## សម្របសម្រួលការចូលទៅកាន់ទីផ្សារប្រកបដោយនិរន្តរភាពសម្រាប់អាជីវកម្មដឹកនាំដោយយុវជន និងពង្រឹងសមត្ថភាពយុវជននូវជំនាញបច្ចេកទេស និងហិរញ្ញវត្ថុក្នុងអាជីវកម្មនិងការកែច្នៃកសិកម្ម (ខ្សែសង្វាក់តម្លៃ)





ផ្ទះលេខ២៨ ផ្លូវលេខ១០០៧ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ. #28, street 1007, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
Mobile: (+855) 17 451 564 / (+855 98 452 581) . Facebook: ខំប្រុជា/Cambodhrra / Cambo DHRRA . www.cambodhrra.org

## រៀបចំក្រុមយុវជននៅតាមជនបទ ឬក្រុមកសិករវ័យក្មេង



## ផ្តល់ការលើកទឹកចិត្ត ឬរង្វាន់ដល់កសិករវ័យក្មេងក្នុងបច្ចេកវិទ្យាកសិកម្ម និងផលិតភាពកសិកម្ម



## ធ្វើសមាហរណកម្មកសិកម្មនៅក្នុងកម្មវិធីសិក្សារបស់សាលាដើម្បីទាក់ទាញចំណាប់អារម្មណ៍តាំងពីក្មេង




## លើកកម្ពស់ការចូលរួមចំណែករបស់យុវជន(ស្ត្រី និងបុរស)ក្នុងការធ្វើកសិកម្មជាលក្ខណៈគ្រួសារ



## ពង្រឹងកម្មវិធីដែលមានស្រាប់ និងច្នៃប្រឌិតថ្មីដែលផ្តល់នូវការលើកទឹកចិត្តកាន់តែច្រើនដល់កសិករវ័យក្មេង



## ធានាអោយមានភាពជាតំណាងរបស់យុវជនចូលរួមក្នុងការអភិវឌ្ឍគោលនយោបាយ និងកម្មវិធីវិស័យកសិកម្ម



## ៥. ករណីសិក្សា យុវជនក្នុងការវិនិយោគកសិកម្ម

### បង្កើតការងារខ្លួនឯងក្រោយរៀនចប់នៅបរទេស



លោក **ខន សំភាស់** ជាយុវសិករស់នៅភូមិតាំងពោធិ៍ ឃុំប្រាំបីមុំ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។ បន្ទាប់ពីបានបញ្ចប់ការសិក្សាផ្នែកវិទ្យាសាស្ត្រកសិកម្ម នៅសាកលវិទ្យាល័យភូមិកសិកម្ម សំភាស់បានបន្តការសិក្សានៅប្រទេសអ៊ីស្រាអែលផ្នែកកសិកម្ម ។ ដោយយល់ឃើញថា មានឱកាសច្រើនជាពិសេស មានធនធានស្រាប់ ដូចជាទឹក ដីកសិកម្ម ព្រមទាំងចង់បំលែងដីនេះទៅជាដីដែលអាចបង្កើតចំណូលបានផង សំភាស់បានសម្រេចចិត្តចាប់យកអាជីពជាអ្នកដាំដុះដំណាំបន្លែ និងផ្តល់សេវារៀបចំប្រព័ន្ធទឹកតាមកសិដ្ឋាន។

ដោយសារកង្វះខាតដើមទុន សំភាស់ចាប់ផ្តើមដាំបន្លែដំបូងលើដីតែកន្លះហិកតាប៉ុណ្ណោះ តែក្នុងរយៈពេល១ឆ្នាំការដាំដុះបន្លែពង្រីកបានរហូតដល់លើផ្ទៃដី៣ហិកតា ហើយអាចរកចំណូលបានប្រមាណជាង ១លានរៀល ក្នុង១ថ្ងៃ។

តាមបទពិសោធន៏ផ្ទាល់ខ្លួន សំភាស់បានបញ្ជាក់ថាដើម្បីអោយអាជីវកម្មជោគជ័យមានកត្តាជាច្រើន តែកត្តាដែលសំខាន់ជាងគេសំរាប់សំភាស់ គឺ ទី១ គឺទឹកចិត្តស្រលាញ់ និងទី២ មានចំណេះដឹង និងបច្ចេកទេសច្បាស់លាស់។

ជាទស្សនៈផ្ទាល់ខ្លួនសំភាស់យល់ថា ដើម្បីទាក់ទាញយុវជនងាកមករកវិស័យកសិកម្ម គឺការអនុវត្តកសិកម្មបែបទំនើប ដោយប្រើប្រាស់នូវបច្ចេកវិទ្យាចុងក្រោយ។

សម្រាប់ផែនការអនាគត សំភាស់នឹងរៀបចំកសិដ្ឋានអោយមានរចនាសម្ពន្ធ័ល្អពង្រឹងគុណភាពអោយត្រូវតាមស្តង់ដាការអនុវត្តន៍កសិកម្មល្អ(GAP) ។

សូមបញ្ជាក់ថា ក្រោមការគាំទ្ររបស់ខាំប្ជ្រា ក្រុមយុវជនមួយដែលផ្តោតលើការវិនិយោគកសិកម្ម ត្រូវបានបង្កើតឡើងលើសពីនេះពួកគេក៏ទទួលបាននូវវគ្គបណ្តុះបណ្តាលនានាពីខាំប្ជ្រា និង សមាគមបណ្តាញកសិករ និងធម្មជាតិ (អេហ្វ អិន អិន) មានដូចជា គំនិតជាសហគ្រិន ផែនការអាជីវកម្ម ការរៀបចំផែនការហិរញ្ញវត្ថុ និងការជ្រើសរើសមុខដំណាំដែលសមស្រមទៅតាមតំរូវការទីផ្សារជាដើម។

## ឈប់ធ្វើការអោយគេដោយចំណាកស្រុក មកធ្វើការអោយខ្លួនឯង



ជាអតីតពលករនៅប្រទេសកូរ៉េ **លោកស្រី អ៊ុក សុភាព** ជាកសិករវ័យក្មេង រស់នៅភូមិបឹង ឃុំបឹងនិមល ស្រុកឈូក ខេត្តកំពត មានអាជីពជាអ្នកចិញ្ចឹមមាន់ស្រែ។

សុភាព បានចិញ្ចឹមមេមាន់យកស៊ុតដើម្បីភ្ញាស់កូនមាន់ផ្គត់ផ្គង់អោយអ្នកចិញ្ចឹមមាន់សាច់ បន្តពីឪពុកតាំងពីឆ្នាំ២០១៨ ក្រោយពីបានត្រឡប់មកពីធ្វើការជាពលករនៅប្រទេសកូរ៉េវិញ ដែលពេលនោះ សុភាពមានមេមាន់ប្រមាណតែជាង១០០ក្បាលប៉ុណ្ណោះ[1]។ សព្វថ្ងៃ សុភាពមានមេមាន់ប្រមាណ ៧០០ក្បាល ហើយអាចភ្ញាស់កូនលក់ជារៀងរាល់សប្តាហ៍ ប្រមាណ ៤០០ ទៅ៥០០ក្បាល ដែលមានតម្លៃ ៣៥០០រៀល សម្រាប់កូនមាន់១ក្បាល។

បន្ទាប់ពីទទួលបានការបណ្តុះគំនិតពីលោកឪពុក អោយស្រលាញ់ការងារកសិកម្ម សុភាពបានឈប់ធ្វើការងារនៅកូរ៉េ ហើយត្រឡប់មកស្រុកកំណើតវិញ ដើម្បីចាប់ផ្តើមអាជីពជាអ្នកចិញ្ចឹមមាន់បន្តពីឪពុក។ សុភាព យល់ឃើញថាការងារកសិកម្មក៏ជាការងារល្អដែរ ដែលធ្វើអោយជីវភាពគ្រួសារមានការផ្លាស់ប្តូររហូតមកដល់សព្វថ្ងៃ ដោយមិនបាច់ចំណាកស្រុក និងធ្វើការអោយគេ។ ជាផែនការ សុភាពនឹងពង្រីកការចិញ្ចឹមមាន់បន្ថែមទៀត ទាំងមាន់មេ និងមាន់សាច់ដើម្បីបង្កើនប្រាក់ចំណូលបន្ថែមសម្រាប់លើកកម្ពស់ជីវភាពគ្រួសារ។

ដើម្បីទាក់ទាញយុវជនងាកមកធ្វើការងារកសិកម្ម សុភាព បានប្តេជ្ញាចិត្តផងដែរថានឹងធ្វើជាគំរូដល់យុវជនដទៃទៀត ដោយបង្ហាញអោយឃើញថា កសិកម្មពិតជាការងារល្អ និងចំណូលខ្ពស់។

តាមរយៈបទពិសោធន៍ផ្ទាល់ខ្លួនជាពលករចំណាកស្រុកម្នាក់ សុភាព សំណូមពរដល់យុវជនដែលបានធ្វើការងារកសិកម្មហើយ បន្តលើកទឹកចិត្តខ្លួនឯងកុំបោះបង់ឆន្ទៈរបស់ខ្លួន ដើម្បីបង្កើតការងារអោយខ្លួនឯងព្រោះធ្វើការងារអោយគេមិនស្រួលដូចមានការងារខ្លួនឯងទេ។ បើយើងមានការងារខ្លួនឯង យើងកាន់តែប្រឹងប្រែងចំណូលបានកាន់តែច្រើនមុខរបរកាន់តែធំ។

[1] ឪពុកសុភាពចាប់ផ្តើមចិញ្ចឹមនៅឆ្នាំ២០១៤



## នៅសិក្សាក៏អាចធ្វើការងារកសិកម្មបានដែរ

កញ្ញា **ជា សៀងឡា** រស់នៅភូមិក្រាំងចំបក់ ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ជានិស្សិតឆ្នាំទី៤ នៃវិទ្យាស្ថានមួយ នៅខេត្តកំពង់ស្ពឺ និងជាយុវកសិករដែលប្រកបរបរកសិកម្មចំរុះ មានដូចជា បន្លែ មាន់ ផ្សិតចំបើង និងត្រីជាដើម។

ដោយសារការស្រលាញ់ និងជាចំណង់ចំណូលចិត្តផ្ទាល់ខ្លួនព្រមទាំងមើលឃើញឱកាសដ៏មានសក្តានុពល ក្នុងការក្តោបក្តាប់ទីផ្សារ បានជំរុញអោយ សៀងឡា សំរេចចិត្តចាប់យកអាជីពនេះ។ ដំបូងឡើយ សៀងឡា ដាំបន្លែ លើផ្ទៃដីតិចតួចប៉ុណ្ណោះ តែក្រោយពីទទួលបានជោគជ័យ សៀងឡា បានចាប់យកផលិតកម្មកសិកម្មផ្សេងទៀត ដែលអាចរកចំណូលបានពី២លាន ទៅ៣លានរៀលក្នុង១ខែ។



ជាផែនការ ពេលបញ្ចប់ការសិក្សា សៀងឡានឹងមិនធ្វើការអោយគេទេដោយបន្តអាជីបកសិកម្ម និងបំលែងកសិដ្ឋានទៅជាកន្លែងរៀនសូត្រ ដើម្បីផ្តល់ចំណេះដឹងដល់កសិករ និងនិស្សិតដែលចាប់អារម្មណ៍ចង់រៀនសូត្រការងារកសិកម្ម។

សៀងឡា យល់ឃើញថាកត្តាដែលនាំអោយជោគជ័យគឺក្តីស្រលាញ់និងចំណង់ចំណូលចិត្តទៅលើមុខរបរនេះជាកម្លាំងចិត្ត និងថាមពលដ៏សំខាន់ ។ តាមចំណាប់អារម្មណ៍របស់ សៀងឡា មានកត្តាសំខាន់បី ដែលធ្វើអោយយុវជនងាកមករកការងារកសិកម្ម នោះគឺ ទី១ ផ្សព្វផ្សាយអោយយុវជនយល់ដឹងពីសារៈសំខាន់នៃមុខរបរកសិកម្ម ទី២ ការបណ្តុះបណ្តាលអោយយុវជនមានបច្ចេកទេស និងជំនាញ និងទី៣ មានទីផ្សារច្បាស់លាស់។

បន្ទាប់ពីបានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីយុវជន និងទស្សនទាននៃអនាគតកសិកម្មកម្ពុជា ដែលរៀបចំដោយសមាគមខាំប្ជូរួចមកបានធ្វើអោយ សៀងឡា មានទំនុកចិត្ត និងភាពកក់ក្តៅ តាមរយៈការរៀនសូត្រ និងស្វែងយល់ពីភាពជោគជ័យរបស់យុវសហគ្រិន និងវាគ្មិនផ្សេងទៀត ដែលបានចែករំលែក ក្នុងអង្គសិក្ខាសាលា។

សៀងឡា បានផ្តាំផ្ញើទៅដល់យុវជនដទៃទៀតថា ដើម្បីចាប់យកអាជីពអ្វីមួយត្រូវកំណត់ពីចំណង់ចំណូលចិត្តខ្លួនឯងអោយច្បាស់លាស់ កុំខ្លាចហត់ កុំចាំមានពេលត្រូវឆ្លៀតធ្វើវា ហើយធ្វើអោយបានល្អ។


ផ្ទះលេខ២៨ ផ្លូវលេខ១០០៧ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ . #28, street 1007, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
Mobile: (+855) 17 451 564 / (+855 98 452 581) . Facebook: ខាំប្ជូរ/Cambodhrra / Cambo DHRRA . www.cambodhrra.org

## ឈប់ពីការងារដែលមានប្រាក់ខែ មកធ្វើការអោយខ្លួនឯង



ជាអតីបុគ្គលិកក្រុមហ៊ុនឯកជនមួយ **លោក ហ៊ិន ផានី** រស់នៅភូមិត្រពាំងឈូក ឃុំនិទាន ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។ ក្រោយពីបានឃើញកសិដ្ឋានចិញ្ចឹមមាន់តូចមួយ ផានីក៏បានចាប់អារម្មណ៍លើមុខរបរចិញ្ចឹមមាន់ ហើយបានលាឈប់ពីការងារនៅក្រុមហ៊ុន ដែលបានប្រាក់ខែ២៨០ដុល្លា ងាកមកចាប់អាជីពជាអ្នកចិញ្ចឹមមាន់សាច់ផ្គត់ផ្គង់ទីផ្សារ និងភ្ញាស់កូនមាន់លក់អោយអ្នកចិញ្ចឹមមាន់សាច់ក្នុងនៅមូលដ្ឋាន។ ផានីបានចិញ្ចឹមមេមាន់ពូជចំនួន៣៥០ក្បាល ដែលអាចផលិតកូនសម្រាប់លក់ចំនួន២ដង ក្នុង១ខែ ហើយអាចរកចំណូលបានចន្លោះពី១លាន៦០ម៉ឺនរៀល ទៅ ២លានរៀល និងមាន់ចិញ្ចឹមយកសាច់ចន្លោះពី៧០០ ទៅ១០០០ក្បាល ក្នុង១ខែ ដែលអាចចំណេញ បានក្នុងមួយវគ្គចន្លោះពី៧ ទៅ១០លានរៀល ក្រោយពីកាត់ចំណាយលើកម្មករ អគ្គិសនី ចំណីថ្នាំ និងការហូបចុក។

ក្រោយពីជួបបញ្ហាចិញ្ចឹមមាន់ចំនួន៣វគ្គ ក្នុងចំណោមការចិញ្ចឹមមាន់៦វគ្គរួចមក ផានីបានស្វែងយល់ពីឫសគល់ នៃបញ្ហានោះ ក្រោយមកផានីបានរកវិធីសាស្រ្តដោះស្រាយបញ្ហានោះបានជោគជ័យ។

ផានី មានចំណាប់អារម្មណ៏លើការចិញ្ចឹមមាន់យកកូន ច្រើនផ្នែកផ្សេងទៀតនៃប្រពន្ធ័ផលិតកម្មមាន់ ដោយសារកត្តាផ្ទាល់ខ្លួនមានសមត្ថភាពគ្រប់គ្រងកូនមាន់បានល្អ និងបរិយាកាសអំណោយផលពីខាងក្រៅមានដូចជា ការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ។ ផានី មានក្តីស្រម៉ៃចង់មានកសិដ្ឋានធំមួយ ដែលចិញ្ចឹមសត្វ ច្រើនមុខ!

កន្លងមក ផានីបានចូលរួមវគ្គបណ្តុះបណ្តាលជាមួយសមាគមបណ្តាញកសិករ និងធម្មជាតិ និងខាំបូជ្រា ទាក់ទងនឹងការធ្វើផែនការអាជីវកម្ម ការចងក្រងជាក្រុមផលិតដើម្បីពង្រឹងអំណាចចរចារជាមួយឈ្មួញចូលរួមសិក្ខាពិគ្រោះយោបល់ស្តីពី យុវជន និងទស្សនទានឆ្ពោះទៅអនាគតកសិកម្មកម្ពុជា និងសិក្ខាសាលាផ្សេងៗទៀត។

ផានី សង្ឃឹមថាវិស័យកសិកម្មកម្ពុជានឹងរីកចំរើនគ្រប់ផ្នែកបន្តិចម្តងៗ ដោយសារយើងមានបច្ចេកវិទ្យាទំនើប និងការគាំទ្រនានា។ មួយវិញទៀតសម្រាប់យុវជនដែលចង់រៀនពីបច្ចេកទេសចិញ្ចឹមមាន់ពីផានី ផានីនឹងជួយបង្រៀនដោយមិនគិតប្រាក់ឡើយ ហើយផ្តល់អាហារជូន និងចែកពូជមាន់យកទៅចិញ្ចឹមខ្លះទៀត ឬលក់មាន់ក្នុងតម្លៃធូរថ្លៃ។

ផានី បានផ្តាំផ្ញើទៅដល់យុវជនដទៃទៀតថាវិស័យកសិកម្ម គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចប្រទេសជាតិ យើងគួរតែប្រឹងប្រែងទាំងអស់ ដើម្បីផលិតអាហារដែលមានសុវត្ថិភាពជូនប្រជាជនយើង។

# ឯកសារយោង

(2014). Principles for Responsible Investment in Agriculture and Food Systems. United Nation's Committee on World Food Security.

(2018). ASEAN Guidelines on Promoting Responsible Investment in Food, Agriculture and Forestry. ASEAN Secretariat (with technical support of the International Institute for Sustainable Development).

Riggs, Michael. (2019). Strengthening Capacities of Youth to Carry Out and Benefit from Responsible Agricultural Investment. Food and Agriculture Organization of the United Nations (FAO). Presentation made during the Capacity Identification Workshop held in Hanoi, Viet Nam last 19-21 June 2019.

(2019). Empowering youth to engage in responsible investment and food systems: challenges, opportunities and lessons learned from six African countries (Côte d'Ivoire, Malawi, Mozambique, Namibia, South Africa and Uganda). Rome, Food and Agriculture Organization of the United Nations (FAO).

(2019). Strengthening Capacities of Youth to Carry Out and Benefit from Responsible Agricultural Investments in SADC Countries: Capacity Identification Workshop. Hanoi, Viet Nam. AsiaDHRRA and Food and Agriculture Organization of the United Nations (FAO).

(2020). Rapid Capacity Assessment Report "Youth Empowerment on Responsible Investment on Agriculture and Food Systems (RAI/CFS)" in Cambodia. CamboDHRRA.

(2020). Monograph on the United Nations Committee on World Food Security's Principles of Responsible Agriculture Investment in Agriculture and Food Systems (CFS-RAI) and the ASEAN Guidelines for Responsible Investment in Food, Agriculture and Forestry (AGRAI). Philippines. AsiaDHRRA.

(2020). Strengthening Capacities of Youth to Carry Out and Benefit from Responsible Agricultural Investments in Cambodia: Capacity Identification Workshop. Phnom Penh, Cambodia. CamboDHRRA. (2020).

(2020) Consultation workshop on Youth and the outlook towards the future of Cambodian agriculture. Phnom Penh, Cambodia. CamboDHRRA.


ផ្ទះលេខ២៨ ផ្លូវលេខ១០០៧ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ . #28, street 1007, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia
Mobile: (+855) 17 451 564 / (+855 98 452 581) . Facebook: ខំប្រជ្រៅ/Cambodhrra / Cambo DHRRA . www.cambodhrra.org

ធ្វើការរួមគ្នាដើម្បីអោយប្រសើរឡើងនូវគុណភាពជីវិតកសិករ និងដើម្បីទាំងអស់គ្នា



**សមាគមភាពជាដៃគូកម្ពុជាដើម្បីអភិវឌ្ឍន៍ធនធានមនុស្សនៅជនបទ (ខាំបូជ្រា)**

**Cambodian Partnership for the Development of Human Resources in Rural Areas Association (CamboDHRRA)**

ផ្ទះលេខ២៨ ផ្លូវលេខ១០០៧ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

#28, street 1007, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia

cambodhrrainfo@gmail.com/info@cambodhrra.org

+855 17 451 564/+855 98 452 581

Facebook: ខាំបូជ្រា/Cambodhrra / Cambo DHRRA

www.cambodhrra.org